សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីទូរស័ព្ទដៃ ដោយយើងដឹងហើយថា
ទូរស័ព្ទគឺមានពីរប្រភេទ គឺ ទូរស័ព្ទមានខ្សែ ឬក៏ទូរស័ព្ទលើតុ ហើយនិងទូរស័ព្ទមួយប្រភេទទៀត
គឺជាទូរស័ព្ទដៃ ឬក៏ទូរស័ព្ទចល័ត ដោយសារតែវាមានរាងតូច ងាយស្រួលយកតាមខ្លួន
អញ្ចឹងគេហៅថាទូរស័ព្ទចល័ត ឬក៏ទូរស័ព្ទដៃ ចំណែកឯទូរស័ព្ទលើតុ គឺយើងពិបាកនឹងយកតាមខ្លួន
ដោយសារតែវាមានរាងធំ ហើយវាត្រូវការប្រើប្រាស់ភ្លើងអគ្គិសនីដើម្បីដំណើរការ
ដូច្នេះគេទុកវាតែនៅលើតុតែប៉ុណ្ណោះ ដោយសារតែវាមានភ្ជាប់ជាមួយនឹងខ្សែ
អញ្ចឹងទូរស័ព្ទគឺមានពីរប្រភេទ គឺទូរស័ព្ទដៃនិងទូរស័ព្ទលើតុ ហើយនៅក្នុងរូបភាពនេះ
គឺយើងនឹងនិយាយអំពីទូរស័ព្ទដៃ។

ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ គឺជា រូបខាងមុខនៃទូរស័ព្ទ
បានន័យថាអេក្រង់ទូរស័ព្ទ អញ្ចឹងទូរស័ព្ទដៃគឺមានពីរប្រភេទ ដែលទី ១ គឺទូរស័ព្ទមានគ្រាប់ចុច
ឬក៏ទូរស័ព្ទមានប៊ូតុង រីឯទី ២ គឺទូរស័ព្ទអត់មានគ្រាប់ចុច ឬក៏យើងហៅថា ទូរស័ព្ទប៉ះលើអេក្រង់
ដែលជាសាមញ្ញ ជាទូទៅ ប្រជាជនកម្ពុជា យើងតែងតែហៅថា ទូរស័ព្ទថាច់ស្គ្រីន
អញ្ចឹងទូរស័ព្ទមានពីរប្រភេទ ដែលកាលពីមុនគឺយើងប្រើប្រាស់ទូរស័ព្ទដែលមានគ្រាប់ចុច
ដោយវាមានគ្រាប់ចុចលេខជាច្រើននៅលើទូរស័ព្ទ ក៏ប៉ុន្តែដល់ពេលបច្ចុប្បន្នគឺទូរស័ព្ទកាន់តែទំនើប
អញ្ចឹងគឺអត់មានគ្រាប់ចុចទៀតទេ ដោយយើងគ្រាន់តែយកម្រាមដៃប៉ះលើអេក្រង់របស់វា
គឺយើងអាចបញ្ជាលើទូរស័ព្ទបានតែម្តង អញ្ចឹងនៅក្នុងរូបភាពនេះ គឺជាទូរស័ព្ទមួយ
ដែលអត់មានគ្រាប់ចុច បានន័យថា ទូរស័ព្ទនោះគឺជាទូរស័ព្ទប្រភេទទូរស័ព្ទថាច់ស្គ្រីន
ជាទូរស័ព្ទស៊េរីទំនើប អញ្ចឹងវាអត់មានគ្រាប់ចុចទេ ដូច្នេះនៅពេលដែលយើងចង់បញ្ជាទូរស័ព្ទ
គឺយើងប៉ះទៅលើអេក្រង់តែម្តង ដែលនេះគឺជារូបភាពខាងមុខនៃទូរស័ព្ទ
ដែលយើងឃើញមានស្គ្រីនធំ ឬក៏អេក្រង់មួយធំ ដែលងាយស្រួលក្នុងការមើល
ហើយមានគ្រាប់ចុចចំនួនតែបីតែប៉ុណ្ណោះ ដែលគ្រាប់ចុចបីនេះ
គឺជាគ្រាប់ចុចសម្រាប់បញ្ជាទូរស័ព្ទសំខាន់ៗ អញ្ចឹងវាអត់មានគ្រាប់ចុចច្រើននោះទេ
ក៏ប៉ុន្តែប្រសិនបើទូរស័ព្ទគ្រាប់ចុចគឺមានគ្រាប់ចុចច្រើន អញ្ចឹងយើងឃើញនៅខាងៗ
ខាងៗគឺមានគ្រាប់ចុចពីរទៀតសម្រាប់ដំឡើងសំឡេង និងបន្ថយសំឡេងទូរស័ព្ទ
ដូច្នេះនៅពេលដែលយើងចង់ដំឡើងសំឡេង ឬក៏ចង់បន្ថយសំឡេង យើងគ្រាន់តែចុចប៊ូតុង
គ្រាប់ចុចពីរខាងៗនោះ គឺជាការស្រេច ដែលយើងអាចដំឡើងសំឡេងបាន ឬក៏បន្ថយសំឡេងបាន
តាមការចង់បានរបស់យើង អញ្ចឹងរូបភាពទី ១ គឺជារូបភាពខាងមុខនៃទូរស័ព្ទ។

ចូលដល់រូបភាពទី ២ រូបភាពទី ២ គឺជារូបភាពនៃផ្នែកខាងក្រោយនៃទូរស័ព្ទ
អញ្ចឹងផ្នែកខាងក្រោយនៃទូរស័ព្ទ គឺយើងអត់មានអ្វីច្រើនទេ អញ្ចឹងបានន័យថា

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ផ្នែកខាងក្រោយគឺយើងមានសំបកទូរស័ព្ទជាមួយនឹងថ្មទូរស័ព្ទ អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ២ នេះ គឺជាផ្នែកខាងក្រោយនៃទូរស័ព្ទដែលបិទគម្របរួច
អញ្ចឹងប្រសិនបើយើងដោះគម្របខាងក្រោយនោះចេញ យើងនឹងឃើញមានថ្មទូរស័ព្ទ និងស៊ីមទូរស័ព្ទ ឬក៏ទូរស័ព្ទខ្លះគឺមានអង្គចងចាំ ឬក៏យើងហៅថា memory
អញ្ចឹងទូរស័ព្ទខ្លះមានដូចជា ទូរស័ព្ទ Samsung ឬក៏ទូរស័ព្ទ LG ជាដើម វាមានដាក់អង្គចងចាំបាន ឬក៏ដាក់ memory ក្រៅបាន អញ្ចឹងនៅខាងក្រោយគឺមានស៊ីមទូរស័ព្ទជាមួយនឹងអង្គចងចាំ ប៉ុន្តែទូរស័ព្ទទំនើបខ្លះទៀតគឺអត់មានអង្គចងចាំខាងក្រៅទេ បានន័យថា វាមានអង្គចងចាំនៅក្នុងទូរស័ព្ទតែម្តង ដូចជា iPhone ជាដើម អញ្ចឹងវាអត់មានដាក់ memory ក្រៅបាននោះទេ ដូច្នេះប្រសិនបើយើងដោះគម្របខាងក្រៅចេញ យើងនឹងឃើញមានថ្មទូរស័ព្ទ ក៏ដូចជាកន្លែងដាក់ស៊ីមជាដើម ហើយផ្នែកខាងក្រោយគឺយើងមានកាមេរ៉ាផងដែរ
អញ្ចឹងកាមេរ៉ាផ្នែកខាងក្រោយគឺយើងទុកសម្រាប់ថតរូប ឬក៏ថតវីដេអូផ្សេងៗដែលយើងចង់បាន
អញ្ចឹងយើងប្រើប្រាស់កាមេរ៉ាផ្នែកខាងក្រោយ ចំណែកឯទូរស័ព្ទខ្លះទៀត គឺគាត់មានកាមេរ៉ាខាងមុខផងដែរ អញ្ចឹងប្រសិនបើគាត់ចង់ថតរូបខ្លួនឯង គាត់អាចប្រើកាមេរ៉ាខាងមុខ ហើយប្រសិនបើគាត់ចង់ថតរូបអ្នកដទៃ គាត់អាចប្រើប្រាស់កាមេរ៉ានៅខាងក្រោយ ដូច្នេះរូបភាពទី ២ នេះ គឺយើងនិយាយអំពីផ្នែកខាងក្រោយនៃទូរស័ព្ទ ដែលមានដូចជាកាមេរ៉ា មានថ្មទូរស័ព្ទ មានកន្លែងដាក់ស៊ីម និងមានកន្លែងដាក់អង្គចងចាំ។

ចូលមកដល់រូបភាពទី ៣ នៅក្នុងរូបភាពទី ៣ គឺទូរស័ព្ទនេះ គឺយើងឃើញគាត់កំពុងតែចុចលេខកូដ ដើម្បីដោះសោ អញ្ចឹងទូរស័ព្ទស៊េរីទំនើប ដើម្បីកុំឲ្យគេចូលលេងប៉ះពាល់ទូរស័ព្ទរបស់យើងបាន យើងតែងតែចាក់សោទូរស័ព្ទដោយប្រើប្រាស់លេខកូដសម្ងាត់ អញ្ចឹងជាធម្មតា ទូរស័ព្ទស៊េរីទំនើបខ្លះ គឺគេប្រើប្រាស់លេខកូដសម្ងាត់ រីឯទូរស័ព្ទខ្លះទៀត គេប្រើប្រាស់មុខងារស្កេនក្រយៅដៃ
អញ្ចឹងនៅក្នុងរូបភាពនេះ គឺយើងឃើញមានដៃមួយ ដៃនោះគឺជាដៃខាងស្តាំ គាត់កំពុងតែកាន់ទូរស័ព្ទ ហើយយកមេដៃរបស់គាត់ចុចទៅលើលេខនៅលើទូរស័ព្ទ នៅលើអេក្រង់ទូរស័ព្ទ ដើម្បីបញ្ចូលលេខសម្ងាត់ អញ្ចឹងគាត់ប្រើប្រាស់លេខសម្ងាត់ដើម្បីចាក់សោទូរស័ព្ទរបស់គាត់
អញ្ចឹងនៅពេលដែលទូរស័ព្ទចាក់សោ បានន័យថាទូរស័ព្ទនោះ យើងអត់អាចប្រើប្រាស់បាននោះទេ បានន័យថាអេក្រង់របស់វា ឬក៏មុខងាររបស់វានៅក្នុងទូរស័ព្ទត្រូវបានគាំងទាំងអស់ លុះត្រាតែយើងដោះសោចេញ អញ្ចឹងពីមុនយើងអត់មានលេខសម្ងាត់នោះទេ ទូរស័ព្ទយើងអត់មានលេខសម្ងាត់ទេ ក៏ប៉ុន្តែដល់ពេលបច្ចុប្បន្ន គឺដើម្បីរក្សាសុវត្ថិភាពទិន្នន័យនៅក្នុងទូរស័ព្ទ គឺគេប្រើប្រាស់ការចាក់សោដោយប្រើប្រាស់លេខសម្ងាត់ ហើយប្រសិនបើទូរស័ព្ទទំនើបកាន់តែទំនើប

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺយើងមានមុខងារស្កេនក្រយៅដៃ
ដូច្នេះទាល់តែអ្នកដែលមានក្រយៅដៃដូចទៅនឹងទូរស័ព្ទនោះទើបអាចស្កេនក្រយៅដៃដោះសោបាន
អញ្ចឹងនៅក្នុងរូបភាពទី ៣ គឺជាការដោះសោទូរស័ព្ទដោយប្រើប្រាស់លេខកូដសម្ងាត់។

ចូលមកដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញមានបុរសម្នាក់
ដែលគាត់មានវ័យប្រហែលជាអាយុ ៣០ ឆ្នាំ អញ្ចឹងបុរសនោះគាត់មានសក់ខ្លីពណ៌ខ្មៅ
ហើយមានភ្នែកតូចៗ អញ្ចឹងគាត់ពាក់អាវពណ៌ផ្កាឈូកដៃខ្លី ហើយដៃម្ខាង ជាដៃខាងឆ្វេងរបស់គាត់
ដាក់ចុះ ដាក់ចុះទៅក្រោម ឬក៏ទម្លាក់ចុះក្រោម
រីឯដៃស្តាំរបស់គាត់កំពុងតែកាន់ទូរស័ព្ទដាក់នឹងត្រចៀក អញ្ចឹងជាទូទៅទូរស័ព្ទគឺមានរាងតូច
ហើយសំឡេងវាអត់សូវឮនោះទេ ដូច្នេះដើម្បីនិយាយគ្នា ឬក៏ដើម្បីនិយាយទូរស័ព្ទ
គឺយើងត្រូវការប្រើប្រាស់ យើងយកទូរស័ព្ទនោះទៅដាក់នៅក្បែរត្រចៀករបស់យើងដើម្បីស្តាប់ឮ
អញ្ចឹងនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែទាក់ទងទៅកាន់មិត្តភក្តិរបស់គាត់
ឬក៏ទាក់ទងទៅកាន់ក្រុមគ្រួសាររបស់គាត់ដោយប្រើប្រាស់ទូរស័ព្ទ
ដូច្នេះហើយគាត់យកទូរស័ព្ទដាក់នៅក្បែរត្រចៀកបន្ទាប់ពីគាត់ចុចលេខទូរស័ព្ទហើយ គាត់ខលទៅ
ឬក៏គាត់ហៅទៅមិត្តភក្តិរបស់គាត់ អញ្ចឹងដើម្បីអាចនិយាយគ្នាបាន ដើម្បីនិយាយគ្នាឮ
ហើយឲ្យភាគីម្ខាងទៀតឮ គឺគាត់ត្រូវដាក់ទូរស័ព្ទក្បែរត្រចៀក និងក្បែរមាត់របស់គាត់
ដើម្បីនិយាយគ្នា ដូច្នេះរូបភាពទី ៤ គឺបុរសម្នាក់នោះ
គាត់កំពុងតែនិយាយទូរស័ព្ទទៅកាន់មិត្តភក្តិរបស់គាត់ ឬក៏ទៅកាន់ក្រុមគ្រួសាររបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ គឺជា យើងឃើញដៃមួយកំពុងតែកាន់ទូរស័ព្ទ
ហើយមេដៃកំពុងតែចុចលើអក្សរនៅលើទូរស័ព្ទ បានន័យថាចុចទៅលើអេក្រង់ទូរស័ព្ទដែលមានអក្សរ
អញ្ចឹងបានន័យថាគាត់កំពុងតែលេងសារ ឬក៏គាត់ផ្ញើសារ អញ្ចឹងនៅក្នុងប្រទេសកម្ពុជា
គឺយើងមានកម្មវិធីផ្ញើសារច្រើន បាទ កម្មវិធីដែលយើងប្រើប្រាស់ដើម្បីផ្ញើសារគឺមានច្រើន
ដូចជាកម្មវិធី Line កម្មវិធី WhatsApp កម្មវិធី Messenger ឬក៏កម្មវិធី Viber ជាដើម
អញ្ចឹងគឺមានច្រើន ដូចជា Telegram អីផងដែរ ដោយយើងពេញនិយមលេងនៅក្នុងប្រទេសកម្ពុជា
ហើយកម្មវិធីដែលយើងពេញនិយមលេងជាងគេបំផុតនោះ គឺកម្មវិធី Line និង Messenger
ដែលភាគច្រើនជាទូទៅគឺយុវជន ឬក៏យុវវ័យនៅក្នុងប្រទេសកម្ពុជា
គឺគាត់ចូលចិត្តលេងនៅក្នុងកម្មវិធីទាំងពីរនេះណាស់
ដោយសារតែវាមានភាពងាយស្រួលក្នុងការលេងសារតាមទូរស័ព្ទប្រភេទនេះ
ឬក៏តាមកម្មវិធីប្រភេទនេះ អញ្ចឹងនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែផ្ញើសារទៅកាន់មិត្តភក្តិរបស់គាត់
ឬក៏ទៅកាន់ក្រុមគ្រួសាររបស់គាត់ ដោយយើងឃើញគាត់កំពុងតែសរសេរអក្សរនៅលើសារ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅលើទូរស័ព្ទដើម្បីផ្ញើ ប៉ុន្តែកម្មវិធីទាំងអស់នេះ ដូចជាកម្មវិធី Line កម្មវិធី Messenger ឬក៏កម្មវិធី Viber ជាដើម គឺយើងត្រូវការប្រើប្រាស់អ៊ីនធឺណិតដើម្បីលេង
អញ្ចឹងកាលពីមុននៅពេលដែលទូរស័ព្ទអត់ទាន់មានអ៊ីនធឺណិត គឺយើងប្រើប្រាស់សារនៅក្នុងទូរស័ព្ទ ដើម្បីផ្ញើទៅគ្នាទៅវិញទៅមក ដូច្នេះយើងអត់ចាំបាច់ត្រូវការអ៊ីនធឺណិត
ក៏យើងអាចផ្ញើសារជជែកគ្នាលេងបានដូចគ្នា អញ្ចឹងនៅពេលដែលបច្ចុប្បន្ន
នៅពេលដែលទូរស័ព្ទទំនើប គឺយើងអាចប្រើប្រាស់អ៊ីនធឺណិតបាន
ដូច្នេះយើងអាចប្រើប្រាស់កម្មវិធីអ៊ីនធឺណិតមួយចំនួន ដើម្បីទាក់ទងគ្នា
ដើម្បីសន្សំសំចៃមិនសូវចំណាយលុយច្រើនផងដែរ ដូច្នេះនៅក្នុងរូបភាពទី ៥ នេះ
គឺគាត់កំពុងតែចុចផ្ញើសារជជែកកម្សាន្តទៅកាន់មិត្តភក្តិរបស់គាត់ ឬក៏ទៅកាន់មិត្តស្រីរបស់គាត់
ដើម្បីជជែកគ្នាលេងជំនួសឲ្យការនិយាយទូរស័ព្ទ ព្រោះពេលខ្លះមនុស្សយើង អ្នកខ្លះ
គាត់អត់ចូលចិត្តនិយាយទូរស័ព្ទច្រើននោះទេ ដូច្នេះហើយគាត់ប្រើប្រាស់ការសរសេរ
ជំនួសឲ្យការនិយាយវិញ អញ្ចឹងគាត់មានជម្រើស គឺគាត់ប្រើប្រាស់កម្មវិធីផ្ញើសារជជែកកម្សាន្ត
ដើម្បីជជែកលេងជាមួយមិត្តភក្តិរបស់គាត់ជំនួសឲ្យការនិយាយ។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ គឺយើងឃើញមានដៃមួយ
កំពុងតែកាន់ទូរស័ព្ទដដែល អញ្ចឹងទូរស័ព្ទនោះគឺជាទូរស័ព្ទស្មាតហ្វូន ដែលយើងហៅថា
ទូរស័ព្ទវ៉ៃឆ្លាត ដែលអត់មានគ្រាប់ចុច ហើយអេក្រង់ធំៗ
អញ្ចឹងគាត់កំពុងតែលេងបណ្តាញទំនាក់ទំនងសង្គម គឺយើងហៅថា Facebook
អញ្ចឹងនៅក្នុងរូបភាពនេះគឺគាត់កំពុងតែបើកមើល Facebook របស់គាត់
ថាតើមានមិត្តភក្តិរបស់គាត់បង្ហោះរូបភាពអ្វី ឬក៏បង្ហោះសារអ្វីនៅក្នុងបណ្តាញទំនាក់ទំនងសង្គម Facebook នោះ ដូច្នេះគាត់កំពុងតែឆែកមើល អញ្ចឹងនៅក្នុងរូបភាពនេះ
យើងឃើញមិត្តភក្តិរបស់គាត់ម្នាក់ មិត្តភក្តិរបស់គាត់ម្នាក់
គឺគាត់បានបង្ហោះរូបឆ្មាទៅក្នុងបណ្តាញសង្គម Facebook ផងដែរ អញ្ចឹងយើងឃើញហើយថា
នៅក្នុងនេះគឺមានរូបឆ្មាមួយ កំពុងតែបង្ហោះ ហើយមានអ្នកចូលចិត្តចំនួន ១៥០ នាក់
ហើយមានអ្នកជជែកចំនួន ២០ នាក់ផងដែរ
អញ្ចឹងបានន័យថាមិត្តភក្តិរបស់គាត់បង្ហោះរូបភាពឆ្មាចូលទៅក្នុងបណ្តាញសង្គម Facebook
ចំណែកឯនៅក្នុងប្រទេសកម្ពុជា Facebook គឺជាបណ្តាញសង្គមដែលមានប្រជាប្រិយភាពបំផុត
បានន័យថាមនុស្សម្នាក់ៗចូលចិត្តលេងបណ្តាញសង្គម Facebook ខ្លាំងណាស់ ហើយក្រៅពី Facebook គឺយើងមានបណ្តាញសង្គមផ្សេងៗទៀតផងដែរដែលយើងចូលចិត្តលេង ដូចជា Instagram ជាដើម ដែលភាគច្រើនគឺគាត់ចូលចិត្តបង្ហោះរូបនៅក្នុង Instagram
ហើយចំណែកឯកម្មវិធី Line ផងដែរ ក៏គេមានការបង្ហោះរូបនៅក្នុងកម្មវិធីជជែកកម្សាន្ត Line

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ផងដែរ ដូច្នេះនៅក្នុងប្រទេសកម្ពុជាគឺយើងអាចលេងបណ្ដាញសង្គម Facebook ឬក៏កម្មវិធីបណ្ដាញសង្គមបានច្រើន មានដូចជា Line មានដូចជា Facebook មានដូចជា Instagram ជាដើម អញ្ចឹងនៅក្នុងរូបភាពទី ៦ គឺគាត់ប្រើប្រាស់ទូរស័ព្ទចល័តរបស់គាត់ ទូរស័ព្ទវ៉ៃឆ្លាតរបស់គាត់ ឬក៏ស្មាតហ្វូនហ្នឹង ដើម្បីលេងប្រើប្រាស់បណ្ដាញសង្គម ដើម្បីលេងជាមួយនឹងមិត្តភក្តិរបស់គាត់ ឬក៏ក្រុមគ្រួសាររបស់គាត់។

ចូលមកដល់រូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញមានបុរសម្នាក់អាយុប្រហែលជា ៣០ ឆ្នាំដដែលនោះ ដែលគាត់មានសក់ខ្លី ពាក់អាវដៃខ្លីពណ៌ផ្កាឈូក ស្លៀកខោពណ៌ខ្មៅ អញ្ចឹងបុរសម្នាក់នោះ គាត់កំពុងតែកាន់ទូរស័ព្ទរបស់គាត់ដើម្បីថតសត្វឆ្មា អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ៧ នេះ គឺបុរសនោះ គាត់ប្រើប្រាស់ដៃទាំងសងខាងរបស់គាត់ ឬក៏ដៃទាំងពីររបស់គាត់ កំពុងតែកាន់ទូរស័ព្ទរបស់គាត់យ៉ាងជាប់ ហើយគាត់បើកកាមេរ៉ាទូរស័ព្ទ ឬក៏បើកមុខងារម៉ាស៊ីនថតនៅក្នុងទូរស័ព្ទរបស់គាត់ ដើម្បីថតសត្វឆ្មានៅខាងមុខគាត់នោះផងដែរ ដោយយើងឃើញនៅខាងមុខគាត់គឺមានសត្វឆ្មាមួយពណ៌លឿង អញ្ចឹងសត្វឆ្មាគឺជាសត្វពាហនៈ ឬក៏សត្វជើងបួន អញ្ចឹងយើងឃើញសត្វឆ្មាពណ៌លឿងមួយកំពុងតែអង្គុយ អញ្ចឹងសត្វឆ្មាគឺមានត្រចៀកពីរវែងៗ ហើយមានពុកមាត់នៅនឹងច្រមុះរបស់វាផងដែរ អញ្ចឹងពុកមាត់របស់វាគឺដុះនៅលើមាត់ក្បែរច្រមុះ ហើយពុកមាត់របស់វាគឺវែងៗ វាមានកន្ទុយមួយវែងនៅខាងក្រោយ ហើយកន្ទុយរបស់វាអាចបក់ទៅឆ្វេងទៅស្ដាំបាន ហើយវាមានជើងបួន អញ្ចឹងឆ្មាគឺវាដើរដោយជើងបួន ដោយវាមានរោមជិតខ្លួនតែម្ដង គឺសត្វឆ្មាគឺមានរោម ដែលរោមរបស់វាគឺរោមជិតខ្លួនជុំវិញខ្លួនរបស់វាតែម្ដង អញ្ចឹងខ្លួនរបស់សត្វឆ្មាគឺពោរពេញដោយរោម ហើយនៅក្នុងរូបភាពទី ៧ នេះ សត្វឆ្មាកំពុងតែអង្គុយ ដើម្បីឲ្យបុរសដែលមានវ័យប្រហែល ៣០ ឆ្នាំនោះ គាត់ប្រើប្រាស់ទូរស័ព្ទដៃរបស់គាត់ ដើម្បីបើកកាមេរ៉ាថតរូប យករូបសត្វឆ្មានោះផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញបុរសដែលមានវ័យប្រហែល ៣០ ឆ្នាំដដែលនោះ គាត់កំពុងតែប្រើប្រាស់កាមេរ៉ារបស់គាត់ថតរូបខ្លួនឯង ប៉ុន្តែលើកនេះ គាត់ប្រើប្រាស់កាមេរ៉ាខាងមុខវិញម្ដង ដោយរូបភាពទី ៧ គឺគាត់ប្រើប្រាស់កាមេរ៉ាខាងក្រោយ ដើម្បីថតសត្វឆ្មា ហើយរូបភាពទី ៨ គឺគាត់ប្រើប្រាស់កាមេរ៉ាខាងមុខ ដើម្បីថតរូបខ្លួនឯង ដែលយើងហៅថា selfie អញ្ចឹងនៅក្នុងរូបភាពទី ៨ នេះ គឺគាត់ពាក់អាវដៃខ្លីពណ៌ផ្កាឈូកដដែល ហើយដៃឆ្វេងរបស់គាត់គឺកាន់ទូរស័ព្ទដោយបែរអេក្រង់ ឬក៏បែរផ្នែកខាងមុខទៅរកមុខរបស់គាត់ អញ្ចឹងគាត់ដៃស្ដាំ គាត់លើកដៃម្រាមដៃពីរឡើង ដើម្បីជាសញ្ញាដើម្បីថតរូប ឬក៏ជាស្ដាយរបស់គាត់ដើម្បីថតរូប ហើយគាត់បានបិទភ្នែកស្ដាំមួយចំហៀង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយភ្នែកមួយចំហៀងទៀតរបស់គាត់នោះ គាត់សម្លឹងទៅមើលកាមេរ៉ាទូរស័ព្ទ
អញ្ចឹងដៃស្តាំរបស់គាត់កំពុងតែចុចថតរូបខ្លួនគាត់
បានន័យថាគាត់ថតរូបខ្លួនឯងដោយប្រើប្រាស់កាមេរ៉ាខាងមុខ
អញ្ចឹងទូរស័ព្ទចល័តបច្ចុប្បន្នគឺមានកាមេរ៉ាសងខាង បានន័យថាមានកាមេរ៉ាខាងមុខផង
និងមានកាមេរ៉ាខាងក្រោយផង ដែលកាមេរ៉ាខាងក្រោយយើងអាចថតរូបអ្នកដទៃ
ឬក៏ថតរូបទេសភាពផ្សេងៗ ចំណែកកាមេរ៉ាខាងមុខយើងអាចថតរូបខ្លួនឯង
បានន័យថាយើងថតរូបខ្លួនឯងជាមួយនឹងមិត្តភក្តិ ឬក៏ជាមួយនឹងទីកន្លែងផ្សេងៗ
គឺយើងអាចប្រើប្រាស់កាមេរ៉ាខាងមុខបាន ដូច្នេះ នៅក្នុងរូបភាពទី ៨ នេះ គឺបុរសម្នាក់នោះ
គាត់កំពុងតែយកទូរស័ព្ទ ដើម្បីថតរូបខ្លួនឯង។

បន្ទាប់មកទៀតចូលដល់រូបភាពទី ៩ នៅក្នុងរូបភាពទី ៩ គឺយើងឃើញបុរសដែលមានវ័យប្រហែល
៣០ ឆ្នាំនោះ គឺគាត់ពាក់អាវដៃខ្លីពណ៌ផ្កាឈូកដដែល ប៉ុន្តែលើកនេះ
គឺគាត់អង្គុយនៅលើសាឡុងមួយ ដែលសាឡុងនោះគឺមានពណ៌លឿង អញ្ចឹងបុរសម្នាក់នោះ
គាត់កំពុងតែអង្គុយលើសាឡុង ហើយដៃទាំងពីររបស់គាត់កំពុងតែកាន់ទូរស័ព្ទ
ដោយភ្នែករបស់គាត់គឺកំពុងតែសម្លឹងមើលទូរស័ព្ទ ហើយមុខរបស់គាត់កំពុងតែញញឹម
អញ្ចឹងបានន័យថាគាត់កំពុងតែញញឹមដើម្បីមើលទូរស័ព្ទរបស់គាត់
ដែលយើងឃើញនៅក្នុងរូបភាពទី ៩ នេះ គឺគាត់កំពុងតែមើលវីដេអូក្នុងទូរស័ព្ទ
អញ្ចឹងទូរស័ព្ទដែលមានអេក្រង់ធំៗ គឺយើងងាយស្រួលក្នុងការមើលវីដេអូនៅក្នុងទូរស័ព្ទ
ដោយយើងអត់ចាំបាច់មើលទូរទស្សន៍នោះទេ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៩ នេះ
បុរសម្នាក់នោះ គាត់កំពុងតែមើលវីដេអូ ដូច ដែលវីដេអូនោះគឺជាវីដេអូ
ដែលនៅក្នុងកម្មវិធីបណ្តាញសង្គមផងដែរ គឺកម្មវិធីយូធូប
អញ្ចឹងគាត់កំពុងតែមើលវីដេអូនៅក្នុងកម្មវិធីយូធូបផងដែរ ដោយគាត់មើលបណ្តើរ
និងញញឹមបណ្តើរ អញ្ចឹងទូរស័ព្ទដែលមានអ៊ីនធឺណិត ឬក៏យើងអាចភ្ជាប់ទៅនឹងអ៊ីនធឺណិតបាន
យើងអាចមើលវីដេអូនៅក្នុងបណ្តាញសង្គមយូធូបបានផងដែរ
ដោយមានវីដេអូច្រើននៅក្នុងបណ្តាញសង្គមមួយនេះ
ព្រោះថាបណ្តាញសង្គមយូធូបគឺមានវីដេអូច្រើនដែលយើងអាចចូលមើលបាន
ដោយប្រើប្រាស់អ៊ីនធឺណិត ក៏ប៉ុន្តែក្រៅពីយូធូបគឺយើងអាចបញ្ចូលវីដេអូទៅក្នុងទូរស័ព្ទរបស់យើង
ដើម្បីមើលផងដែរ ប្រសិនបើយើងអត់មានអ៊ីនធឺណិតទេ
គឺយើងអាចបញ្ចូលវីដេអូទៅក្នុងទូរស័ព្ទរបស់យើង ហើយយើងអាចមើលបាន
អញ្ចឹងដូចជាយើងមើល ចង់មើលរឿងផ្សេងៗដែលយូរៗ ហើយយើងអត់ចង់ប្រើប្រាស់អ៊ីនធឺណិត
អញ្ចឹងយើងអាចបញ្ចូលភ្ជាប់ជាមួយទៅនឹងកុំព្យូទ័ររបស់យើង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីបញ្ចូលវីដេអូផ្សេងៗចូលទៅក្នុងទូរស័ព្ទរបស់យើង
ដូច្នេះហើយយើងអាចមើលវីដេអូពីទូរស័ព្ទរបស់យើង ដោយប្រើប្រាស់អ៊ីនធឺណិតផង
និងមិនបាច់ប្រើប្រាស់អ៊ីនធឺណិតផង ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៩ នេះ គឺបុរសម្នាក់នោះ
គាត់កំពុងតែអង្គុយលើសាឡុង ហើយដៃទាំងពីររបស់គាត់កាន់ទូរស័ព្ទដើម្បីមើលវីដេអូពីក្នុងយូធូប។

ចូលមកដល់រូបភាពទី ១០ នៅក្នុងរូបភាពទី ១០ គឺបុរសម្នាក់នោះ យើងឃើញ មានបុរសម្នាក់
ដែលមានវ័យប្រហែល ៣០ ឆ្នាំនោះ ដៃរបស់គាត់ម្ខាងកំពុងតែកាន់ទៅលើរបាររថយន្តក្រុង
ឬក៏រថភ្លើង ហើយដៃម្ខាងទៀតកំពុងតែកាន់ទូរស័ព្ទ ចំណែកត្រចៀកគាត់គឺដោតជាប់ទៅនឹងកាស
បានន័យថាគាត់កំពុងតែស្តាប់ចម្រៀងដោយប្រើប្រាស់កាសស្តាប់ត្រចៀក អញ្ចឹងកាស
យើងឃើញគាត់ពាក់កាសពណ៌ខ្មៅ ដោយយើងឃើញចុងកាសគឺម្ខាងដោតជាប់ទៅនឹងទូរស័ព្ទ
ហើយចុងកាសម្ខាងទៀងគឺភ្ជាប់ទៅនឹងត្រចៀករបស់គាត់ទាំងសងខាង
ដូច្នេះគាត់កំពុងតែស្តាប់ចម្រៀង ដែលយើងឃើញនៅក្បែរគាត់គឺមានអក្សរចម្រៀងហោះឡើងលើ
បានន័យថាគាត់កំពុងតែឈរជិះរថភ្លើងបណ្តើរ ឬក៏ជិះឡានក្រុងបណ្តើរ ស្តាប់ចម្រៀងបណ្តើរ
ដែលយើងឃើញនៅក្បែរគាត់គឺមានមនុស្សជាច្រើនទៀតផងដែរ
ដូចជានៅខាងក្រោយគាត់គឺមានស្ត្រីម្នាក់ ដែលកំពុងតែស្ពាយកាបូប ឈរនៅក្បែរ
ឈរនៅក្នុងរថយន្តក្រុងនោះជាមួយគ្នា ដោយក្បែរនឹងបុរសម្នាក់ទៀតកំពុងតែឈរដូចគ្នា
អញ្ចឹងមានមនុស្សជាច្រើននៅលើឡានក្រុង ឬក៏នៅលើរថភ្លើងនោះ
កំពុងតែធ្វើដំណើរនៅលើឡានក្រុង ដូច្នេះប្រសិនបើយើងមានទូរស័ព្ទទំនើប
យើងអាចបើកចម្រៀងស្តាប់បណ្តើរ និងឈរជិះលើរថយន្តក្រុងបណ្តើរបាន
ដោយយើងអាចកំដរអារម្មណ៍ ឬក៏កម្សាន្តអារម្មណ៍បាន ដូចជាបុរសម្នាក់នេះ អ្នកនៅក្នុងរូបភាពទី
១០ នេះ គឺគាត់កំពុងតែធ្វើដំណើរទៅកាន់ទីកន្លែងជួបមិត្តភក្តិរបស់គាត់ ប៉ុន្តែនៅលើឡានក្រុង
គឺគាត់ដាក់កាសនៅក្នុងត្រចៀករបស់គាត់ ដើម្បីស្តាប់ចម្រៀងពីក្នុងទូរស័ព្ទ
ដោយសារតែគាត់ប្រើប្រាស់ទូរស័ព្ទទំនើប ដែលអាចចាក់ចម្រៀងបាន
ដូច្នេះកុំឲ្យមានសំឡេងរំខានទៅអ្នកដទៃ ព្រោះថាប្រសិនបើយើងអត់ដាក់កាសទេ
គឺអាចមានសំឡេងរំខានចេញពីក្នុងទូរស័ព្ទទៅកាន់អ្នកដទៃបាន អញ្ចឹងអ្នកដទៃអាចនឹងមិនពេញចិត្ត
ឬក៏គាត់អាចខឹង ដូច្នេះ ប្រសិនបើយើងចង់ស្តាប់ចម្រៀង គឺយើងអាចដាក់កាស
ដើម្បីស្តាប់ម្នាក់ឯងបាន ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១០ បុរសម្នាក់នោះ
គាត់កំពុងតែចាក់ចម្រៀងស្តាប់នៅក្នុងកាសម្នាក់ឯង។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ គឺយើងឃើញដៃមួយកំពុងតែកាន់ទូរស័ព្ទ
ហើយលេងល្បែងកម្សាន្តនៅក្នុងទូរស័ព្ទ អញ្ចឹងទូរស័ព្ទគឺមានមុខងារច្រើន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បានន័យថាយើងអាចប្រើប្រាស់បានច្រើន ទូរស័ព្ទដៃ គឺយើងអាចចាក់ចម្រៀង
យើងអាចមើលជាវីដេអូ យើងអាចទាក់ទងទៅកាន់មិត្តភក្តិរបស់យើង ដែលការនិយាយទូរស័ព្ទ
ឬក៏ការផ្ញើសារ យើងអាចថតរូបបាន ចំណែកឯមុខងារមួយទៀត គឺជាមុខងារល្បែងកម្សាន្ត
បានន័យថា នៅពេលដែលយើងអផ្សុក យើងនៅម្នាក់ឯង អត់មានមិត្តភក្តិនៅជាមួយ
អញ្ចឹងយើងអផ្សុក ដូច្នេះយើងចង់លេងល្បែង យើងអាចលេងល្បែងនៅក្នុងទូរស័ព្ទបាន
បានន័យថាជាល្បែងកម្សាន្ត ឬក៏ជាហ្គេមនៅក្នុងទូរស័ព្ទ ដែលនៅក្នុងរូបភាពនេះ
គឺជាហ្គេមតម្រៀបផ្លែឈើ បានន័យថាយើងត្រូវតម្រៀបផ្លែឈើឲ្យដូចៗគ្នា នោះយើងអាចឈ្នះ
អញ្ចឹងនៅក្នុងទូរស័ព្ទដៃ គឺទាំងអស់ គឺគ្រប់ទូរស័ព្ទដៃ គឺសុទ្ធតែមានល្បែងកម្សាន្ត
ដើម្បីកំដរកុំឲ្យយើងអផ្សុកបាន អញ្ចឹងនៅពេលដែលយើងអផ្សុក នៅពេលដែលយើងនៅម្នាក់ឯង
គឺយើងអាចប្រើប្រាស់ទូរស័ព្ទ ដើម្បីលេងល្បែងកម្សាន្ត ឬក៏លេងហ្គេមនៅក្នុងទូរស័ព្ទបាន
ដោយឥតគិតថ្លៃ បានន័យថាហ្គេមនៅក្នុងទូរស័ព្ទគឺយើងអត់គិតលុយនោះទេ
ដូច្នេះមនុស្សម្នាក់ៗដែលប្រើប្រាស់ទូរស័ព្ទ គឺគាត់ចូលចិត្តលេងហ្គេមនៅក្នុងទូរស័ព្ទគាត់ផងដែរ
ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១១ នេះ
គឺយើងឃើញមានមនុស្សកំពុងតែលេងហ្គេមនៅក្នុងទូរស័ព្ទរបស់គាត់។

ចូលមកដល់រូបភាពទី ១២ នៅក្នុងរូបភាពទី ១២ គឺ ក្រៅពីមុខងារលេងហ្គេមនោះ
យើងឃើញគេអាចប្រើប្រាស់ទូរស័ព្ទរបស់គេ ដើម្បីស្វែងរកទីតាំងផងដែរ
អញ្ចឹងទូរស័ព្ទទំនើបបច្ចុប្បន្នគឺមានប្រព័ន្ធ GPS ដែលយើងហៅថាប្រព័ន្ធ GPS
គឺជាប្រព័ន្ធមួយដែលអាចឲ្យយើងស្វែងរកទីតាំងដែលយើងចង់ទៅបាន
ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១២ នេះ គឺគាត់កំពុងតែស្វែងរកហាងកាហ្វេ
ដែលយើងឃើញគាត់មានអក្សរហាងកាហ្វេនៅលើអេក្រង់ទូរស័ព្ទរបស់គាត់ នៅកន្លែងស្វែងរក
អញ្ចឹងគាត់អាចវាយអក្សរ ឬក៏វាយអក្សរផ្សេងៗ ឬក៏ឈ្មោះទីកន្លែងដែលគាត់ចង់ទៅ
អញ្ចឹងគ្រាន់តែវាយនៅក្នុងកន្លែងស្វែងរក កន្លែងដែលគាត់ចង់ទៅនោះ
ផែនទីនៅក្នុងទូរស័ព្ទនឹងបង្ហាញប្រាប់យើងថាតើយើងត្រូវទៅតាមផ្លូវណាខ្លះ
ដើម្បីទៅដល់ទីកន្លែងដែលយើងចង់ទៅ អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ១២ នេះ
គឺគាត់ប្រើប្រាស់ទូរស័ព្ទរបស់គាត់ ដើម្បីស្វែងរកហាងកាហ្វេ អញ្ចឹងគាត់វាយពាក្យ ហាងកាហ្វេ
ចូលទៅក្នុងកន្លែងស្វែងរក ឬក៏ប្រអប់ស្វែងរក បន្ទាប់មកគាត់ចុចលើពាក្យស្វែងរក
ដូច្នេះផែនទីនោះនឹងបង្ហាញទីតាំងហាងកាហ្វេដែលគាត់ចង់ទៅ
ហើយនិងទីតាំងដែលគាត់កំពុងតែនៅ ដូច្នេះគាត់អាចដឹងថាតើដើម្បីពីទីតាំងដែលគាត់កំពុងតែនៅ
ទៅដល់ហាងកាហ្វេដែលគាត់ចង់ទៅ គឺត្រូវប្រើប្រាស់ចំណាយពេលប៉ុន្មាន
ហើយនិងត្រូវទៅតាមផ្លូវណាខ្លះ ដូច្នេះយើងមានភាពងាយស្រួល

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយយើងអត់ចាំបាច់កាន់ផែនទីធំៗនៅក្នុងដៃយើងនោះទេ
គឺយើងគ្រាន់តែប្រើប្រាស់ទូរស័ព្ទចល័តរបស់យើង ដើម្បីស្វែងរកផ្លូវដែលយើងចង់ទៅ
គឺងាយស្រួលជាងការកាន់ផែនទីធំៗនៅក្នុងខ្លួន
ដែលវាពិបាកនៅក្នុងការទុកដាក់នៅក្នុងខ្លួនរបស់យើង ដូច្នេះយើងអាចប្រើប្រាស់ទូរស័ព្ទ
ដើម្បីជាកម្មវិធីសម្រាប់នាំផ្លូវរបស់យើងទៅកាន់ទីកន្លែងដែលយើងចង់ទៅបាន
ដែលជាក់ស្ដែងនៅក្នុងរូបភាពទី ១២ នេះ គឺគេប្រើប្រាស់ទូរស័ព្ទ ដើម្បីស្វែងរកហាងកាហ្វេ
ដើម្បីទៅញ៉ាំកាហ្វេ ឬក៏ដើម្បីទៅជួបមិត្តភក្ដិរបស់គេនៅទីនោះ។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ គឺយើងឃើញទូរស័ព្ទចល័តដដែល
ប៉ុន្តែលើកនេះគឺគេបើកកម្មវិធីប្រតិទិន បានន័យថានៅក្នុងទូរស័ព្ទមួយ
គឺមានមុខងារច្រើនៗមែនទែន បានន័យថាយើងអាចប្រើប្រាស់វាបានច្រើនប្រភេទ
ដោយយើងអាចលេងហ្គេមផង យើងអាចមើលវីដេអូ យើងអាចស្ដាប់ចម្រៀង
យើងអាចទាក់ទងទៅមិត្តភក្ដិ ហើយក៏យើងអាចដឹងអំពីថ្ងៃខែ ឬក៏ដឹងអំពីកាលបរិច្ឆេទបាន
អញ្ចឹងយើងអាចដឹងអំពីថ្ងៃខែ ឬក៏កាលបរិច្ឆេទបាននៅក្នុងទូរស័ព្ទរបស់យើង
ដោយយើងប្រើប្រាស់កម្មវិធីប្រតិទិន អញ្ចឹងនៅក្នុងរូបភាពនេះ
គឺគាត់ចង់ដឹងថាតើថ្ងៃនេះជាថ្ងៃទីប៉ុន្មាន ឬក៏មិត្តភក្ដិរបស់គាត់មានខួបកំណើតនៅក្នុងថ្ងៃណា
អញ្ចឹងគាត់អាចបើកទូរស័ព្ទរបស់គាត់ ដើម្បីឆែកមើលប្រតិទិនបាន
អញ្ចឹងនៅក្នុងប្រតិទិនគឺយើងអាចឆែកមើលថាថ្ងៃនេះជាថ្ងៃទីប៉ុន្មាន
ហើយក៏យើងអាចសរសេរនៅការចងចាំរបស់យើងមួយចំនួន ឬក៏ការកត់ត្រាមួយចំនួន
ថាតើថ្ងៃទីប៉ុន្មាន យើងមានកម្មវិធីអី ដូចជាឧទាហរណ៍ថា នៅក្នុងថ្ងៃទី ១០ ខែ មេសា ឬក៏ថ្ងៃទី ១០
ខែ សីហា គឺគាត់មានកម្មវិធីខួបកំណើតមិត្តភក្ដិរបស់គាត់
ដូច្នេះគាត់អាចសរសេរកត់ត្រាទុកនៅលើប្រតិទិនរបស់គាត់ ថានៅថ្ងៃទី ១០
គឺមានខួបកំណើតមិត្តភក្ដិ ដូច្នេះនៅពេលដែលថ្ងៃទី ១០ គឺទូរស័ព្ទនឹងរោទ៍ឡើង ដើម្បីរំលឹកយើងថា
យើងមានកម្មវិធីនៅក្នុងថ្ងៃនោះ ដូច្នេះវាងាយស្រួលជាងការប្រើប្រាស់ប្រតិទិននៅខាងក្រៅ
បានន័យថានៅប្រតិទិនខាងក្រៅគឺយើងត្រូវការកត់ត្រាទុកចាំខ្លួនឯង ហើយយើងត្រូវការរំលឹក
ក៏ប៉ុន្តែប្រសិនបើយើងប្រើប្រាស់ប្រតិទិននៅក្នុងទូរស័ព្ទ គឺងាយស្រួល
គឺទូរស័ព្ទនឹងជាអ្នករំលឹកយើងតែម្ដង ថាយើងនៅក្នុងថ្ងៃនេះគឺយើងត្រូវធ្វើអ្វីខ្លះ ត្រូវធ្វើអ្វីខ្លះ
គឺទូរស័ព្ទជាអ្នករំលឹកយើងតែម្ដង
ដូច្នេះគឺមានភាពងាយស្រួលក្នុងការប្រើប្រាស់ប្រតិទិននៅក្នុងទូរស័ព្ទ
ដែលជាក់ស្ដែងនៅក្នុងរូបភាពទី ១៣ គឺគាត់កំពុងតែមើលប្រតិទិនដែលនៅក្នុងទូរស័ព្ទរបស់គាត់។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចូលមកដល់រូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ គឺយើងប្រើប្រាស់ទូរស័ព្ទរបស់យើង ដើម្បីវាស់សីតុណ្ហភាព អញ្ចឹងដើម្បីចង់ដឹងពីសីតុណ្ហភាពពីមុន នៅពេលដែលអត់ទាន់មានទូរស័ព្ទ គឺយើងប្រើប្រាស់សីតុណ្ហមាត្រ បានន័យថាប្រដាប់វាស់សីតុណ្ហភាព អញ្ចឹងគឺយើងប្រើសីតុណ្ហមាត្ររបស់យើងដាក់នៅលើថ្ងៃ ឬក៏ដាក់នៅក្នុងផ្ទះរបស់យើង ដើម្បីដឹងថា តើថ្ងៃនេះមានសីតុណ្ហភាពចំនួនប៉ុន្មានអង្សា ក៏ប៉ុន្តែនៅពេលបច្ចុប្បន្ន គឺយើងអត់ត្រូវការសីតុណ្ហមាត្រដើម្បីវាស់សីតុណ្ហភាពនោះទេ គឺយើងអាចប្រើប្រាស់ទូរស័ព្ទរបស់យើងដើម្បីដឹងអំពីសីតុណ្ហភាពប្រចាំថ្ងៃបាន ដោយសារតែទូរស័ព្ទដៃឥឡូវគឺ ឬក៏ទូរស័ព្ទដៃបច្ចុប្បន្នគឺមានភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត ដូច្នេះវាអាចទទួលទិន្នន័យពីលើអ៊ីនធឺណិតបានថាតើថ្ងៃនេះ នៅតំបន់ដែលយើងកំពុងតែរស់នៅ មានសីតុណ្ហភាពប៉ុន្មាន? ហើយថ្ងៃស្អែកមានសីតុណ្ហភាពប៉ុន្មាន? ហើយមានភ្លៀងដែរឬទេ? ដូច្នេះយើងអាចតាមដានសីតុណ្ហភាពប្រចាំថ្ងៃនៅក្នុងតំបន់របស់យើងរស់នៅ តាមរយៈទូរស័ព្ទដៃរបស់យើងបាន ហើយប្រសិនបើយើងប្រើប្រាស់សីតុណ្ហមាត្រនៅខាងក្រៅ ដើម្បីវាស់សីតុណ្ហភាព គឺយើងអាចដឹងតែនៅក្នុងបរិវេណតំបន់ដែលយើងរស់នៅតែប៉ុណ្ណោះ ក៏ប៉ុន្តែប្រសិនបើយើងប្រើប្រាស់ទូរស័ព្ទដៃ គឺយើងអាចឆែកដឹងតំបន់ផ្សេងៗទៀតផងដែរ ឬក៏ប្រទេសផ្សេងទៀតផងដែរ ដូចជាយើងចង់ទៅក្រៅប្រទេស អញ្ចឹងយើងចង់ដឹងថាតើ នៅក្នុងបច្ចុប្បន្នគឺ នៅក្រៅប្រទេសនោះគឺជារដូវត្រជាក់ឬក៏រដូវក្ដៅ យើងអាចឆែកមើលនៅក្នុងទូរស័ព្ទរបស់យើងថា តើប្រទេសដែលយើងចង់ទៅនោះ មានសីតុណ្ហភាពប៉ុន្មាន អញ្ចឹងគឺយើងអត់ចាំបាច់ទំនាក់ទំនងទៅសួរអ្នកណា ដែលនៅប្រទេសនោះៗទេ យើងគ្រាន់តែឆែកនៅក្នុងទូរស័ព្ទរបស់យើង គឺយើងអាចដឹងសីតុណ្ហភាពបានដូចគ្នា អញ្ចឹងនៅក្នុងរូបភាពទី ១៤ គឺគេប្រើប្រាស់ទូរស័ព្ទដៃ ដើម្បីឆែកសីតុណ្ហភាព។

ចូលមកដល់រូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ គឺយើងឃើញ រូបភាពទូរស័ព្ទដដែល ប៉ុន្តែជាអេក្រង់ផ្នែកខាងលើ អញ្ចឹងអេក្រង់ផ្នែកខាងលើទូរស័ព្ទ គឺយើងឃើញមានបង្ហាញរូបភាពសេវាទូរស័ព្ទ រូបភាពសេវាអ៊ីនធឺណិត រូបភាពម៉ោង ឬក៏ពេលវេលា និងរូបភាពថ្ម អញ្ចឹងបានន័យថា ថាមពលរបស់ទូរស័ព្ទនៅក្នុងរូបភាពនេះគឺជិតអស់ហើយ គឺបានន័យថាមានតែ ២៦ ភាគរយតែប៉ុណ្ណោះ អញ្ចឹងថាមពលដែលគាត់ប្រើប្រាស់គឺពេញមួយថ្ងៃ អញ្ចឹងធ្វើឲ្យថាមពលថ្មរបស់ទូរស័ព្ទ គឺអស់ អស់ថ្មទូរស័ព្ទ ដូច្នេះទូរស័ព្ទគឺនៅតែ ២៦ ភាគរយតែប៉ុណ្ណោះ ដូច្នេះគាត់អត់ អត់ចង់ប្រើប្រាស់ទូរស័ព្ទរបស់គាត់ទៀតទេ អញ្ចឹងប្រសិនបើយើងប្រើប្រាស់រហូតទាល់តែអស់ថាមពលទូរស័ព្ទ ទូរស័ព្ទនឹងរលត់ ដូច្នេះដើម្បីកុំឲ្យទូរស័ព្ទរលត់ អញ្ចឹងយើងអត់ត្រូវប្រើប្រាស់ឲ្យអស់ថ្មនោះទេ បានន័យថាយើងសល់ថ្ម

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

១០ ភាគរយ ឬក៏ ២០ ភាគរយ យើងត្រូវបញ្ចូលថ្ម ឬក៏សាកថ្មឡើងវិញ ដែលនៅក្នុងរូបភាពទី ១៥ នេះ គឺបង្ហាញអំពីផ្នែកខាងលើនៃអេក្រង់ទូរស័ព្ទ ដែលមានដូចជាសេវាទូរស័ព្ទដៃ សេវាអ៊ីនធឺណិត ម៉ោង ជាមួយនឹងថ្មទូរស័ព្ទដែលកំពុងតែជិតអស់ ដែលនៅសល់ ២៦ ភាគរយ។

ចូលមកដល់រូបភាពចុងក្រោយ គឺរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា បន្ទាប់ពីថ្មទូរស័ព្ទរបស់គាត់ជិតអស់ អញ្ចឹងគេក៏យកទូរស័ព្ទមកសាកទៅនឹងអគ្គិសនី បានន័យថាគាត់សាកថ្មឡើងវិញ ឬក៏បញ្ចូលថ្ម អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញទូរស័ព្ទចល័តរបស់គាត់កំពុងតែដោតជាប់ខ្សែមួយ ដែលចុងម្ខាងភ្ជាប់ជាមួយនឹងទូរស័ព្ទ ហើយចុងម្ខាងទៀតភ្ជាប់ជាមួយនឹងព្រីភ្លើង បានន័យថាជាឌុយភ្លើង ហើយគាត់ដោតចូលទៅក្នុងព្រីភ្លើង ដើម្បីសាកថ្មទូរស័ព្ទពីក្នុងអគ្គិសនី អញ្ចឹងដើម្បីបញ្ចូលថាមពលទូរស័ព្ទ យើងត្រូវប្រើប្រាស់ថាមពលអគ្គិសនី ដែលនៅក្នុងទីក្រុង គឺយើងអាចប្រើប្រាស់ភ្លើងអគ្គិសនី រីឯនៅតាមជនបទគឺយើងអាចប្រើប្រាស់ភ្លើងអាគុយ ដើម្បីសាកទូរស័ព្ទ ដូច្នេះនៅក្នុងរូបភាពនេះ គឺគេប្រើប្រាស់ភ្លើងអគ្គិសនី ដើម្បីសាកថ្មទូរស័ព្ទរបស់គេឲ្យមានថាមពលឡើងវិញ ដើម្បីប្រើប្រាស់បន្តទៀត អញ្ចឹងគេអត់អាចប្រើប្រាស់ទូរស័ព្ទរហូតទាល់តែអស់ថ្មនោះទេ ព្រោះវាអាចធ្វើឲ្យទូរស័ព្ទឆាប់ខូចបាន ដូច្នេះ យើង នៅពេលដែលយើងប្រើប្រាស់ថ្មទូរស័ព្ទជិតអស់ យើងអាចបញ្ចូលថ្មឡើងវិញ ដោយប្រើប្រាស់ភ្លើងអគ្គិសនី ឬក៏ភ្លើងអាគុយបាន ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១៦ គឺគេប្រើប្រាស់ភ្លើងអគ្គិសនី ដើម្បីសាកថ្មទូរស័ព្ទ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.